# ព្រះរាជក្រម

នស/រកម/១០០៥/០៣៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយម វៀត ណាម ស្តីពីការជំរុញ និងការការពារវិនិយោគ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ៥ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់

## ស្តីពី

## ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃ
## ព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយម
## វៀតណាម ស្តីពីការជំរុញនិងការការពារវិនិយោគ

មាត្រា ១.-

អនុម័តយល់ព្រមលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាមស្តីពីការជំរុញនិងការការពារវិនិយោគ ដែលធ្វើនៅទីក្រុងភ្នំពេញ នាថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០០១ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

មាត្រា ២.-

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តកិច្ចព្រមព្រៀងនេះ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០០៥

នស/រកម.០៥១០.៤៩១

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ហត្ថលេខា

គាត ឈន់

លេខ ៤៧០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុយ សែម

សុខ ស៊ីដាន់

៩១៦

# កិច្ចព្រមព្រៀង

## រវាង

## រាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា

## និង

## រដ្ឋាភិបាល នៃ សាធារណរដ្ឋ សង្គមនិយម វៀតណាម

## ស្តីពី

## ការជំរុញ និង ការការពារវិនិយោគ

រាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាល នៃ សាធារណរដ្ឋសង្គមនិយម វៀតណាម (ចាប់ពីពេលនេះតទៅហៅថា " ភាគីជាប់កិច្ចសន្យា" )

ក្នុងស្មារតីបង្កើននូវ ទំនាក់ទំនងមិត្តភាព និង សហប្រតិបត្តិការដែលមានស្រាប់ រវាងប្រទេស និង ប្រជាជនទាំងពីរ

ដោយមានគោលបំណងបង្កើតនូវល័ក្ខខ័ណ្ឌអនុគ្រោះសំរាប់ដំណើរការវិនិយោគ ដែលធ្វើឡើងដោយជនជាតិរបស់ភាគីជាប់កិច្ចសន្យាមួយ ឈរលើមូលដ្ឋានអធិបតេយ្យភាព ស្មើភាព និងមានផលប្រយោជន៍ទៅវិញទៅមក និង

ដោយទទួលស្គាល់ថាកិច្ចព្រមព្រៀង ស្តីពី ការជំរុញ និង ការការពារវិនិយោគនេះ នឹងជំរុញអោយមានការកើនឡើងនូវសកម្មភាពផ្នែកវិនិយោគនៅក្នុងប្រទេសទាំងពីរ

**ភាគីទាំងពីរបានព្រមព្រៀងគ្នាដូចតទៅ :**

## មាត្រា ១

## និយមន័យ

**គោលបំណងនៃកិច្ចព្រមព្រៀងនេះ :**

១. ពាក្យ " វិនិយោគ " គឺសំដៅទៅលើរាល់ទ្រព្យសម្បត្តិ ដែលបានដាក់សំរាប់វិនិយោគ ដោយជនជាតិនៃភាគីជាប់កិច្ចសន្យាមួយនៅលើទឹកដី នៃភាគីជាប់កិច្ចសន្យាម្ខាងទៀត និង បានទទួលស្គាល់ដោយអនុលោមទៅតាម ច្បាប់ និង បទបញ្ញត្តិនានារបស់ភាគីជាប់កិច្ចសន្យាក្រោយនេះដែលក្នុងនោះរួមមានទ្រព្យសម្បត្តិដូចខាងក្រោម តែមិនកំរិតទាំងស្រុងត្រឹមទ្រព្យសម្បត្តិទាំងនេះឡើយនូវៈ

ក- ចលនៈទ្រព្យ និង អចលនៈទ្រព្យ ព្រមទាំងសិទ្ធិកាន់កាប់ដទៃទៀតដូចជា ការបញ្ចាំ បុព្វសិទ្ធិ និង រាល់ការធានា ព្រមទាំងសិទ្ធិដទៃទៀត ដែលមានលក្ខណៈប្រហាក់ប្រហែល ។

ខ- សិទ្ធិជាភាគហ៊ុន ប័ណ្ណធានា ឬ ផលប្រយោជន៏ផ្សេងទៀត នៅក្នុងក្រុមហ៊ុន នៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ។

គ- ការតវ៉ាពាក់ព័ន្ធករណីភាគហ៊ុន-ប័ណ្ណធានា ឬ ប្រតិបត្តិការណាមួយ ដែលមានតំលៃហិរញ្ញវត្ថុ ។

ឃ- កម្មសិទ្ធិបញ្ញា ក្បួនខ្នាតបច្ចេកវិជ្ជា កិត្តិនាមជំនួញ និង ស្នាដៃយល់ដឹង ។

ង- សម្បទានធុរៈកិច្ច មានតំលៃសេដ្ឋកិច្ចដែលទទួលស្គាល់ដោយច្បាប់ ឬ តាមកិច្ចសន្យាដែលទាក់ទិននឹងការវិនិយោគ ដោយរួមទាំងសម្បទានសំរាប់ការស្រាវជ្រាវ ឬ ការធ្វើអាជីវកម្មលើធនធានធម្មជាតិ ។

ការប្តូរទ្រង់ទ្រាយនៃទ្រព្យសម្បត្តិដែលបានវិនិយោគ មិនមានឥទ្ធិពលទៅលើចរិតនៃការវិនិយោគដែលបានផ្តល់ជូនឡើយ ក្នុងពេលដែលការប្តូរទ្រង់ទ្រាយនោះត្រូវបានឯកភាព និង ទទួលស្គាល់ក្រោមមាត្រា ២ នៃកិច្ចព្រមព្រៀងនេះ ។

២- ពាក្យ " ជនជាតិ " មានន័យថា

(i) រូបវ័ន្តបុគ្គលដែលមានសញ្ជាតិ របស់ភាគីជាប់កិច្ចសន្យា

(ii) នីតិបុគ្គលដែលបង្កើតឡើងដោយច្បាប់នៃភាគីជាប់កិច្ចសន្យា ។

៣- ពាក្យ " គ្មានការពន្យារពេល " មានន័យថា គឺជារយៈពេល ដែលជាធម្មតាត្រូវការ សំរាប់បំពេញនៃទំរង់បែបបទចាំបាច់ ដើម្បីផ្ទេរប្រាក់ ។

Цп

៤- " ទឹកដី " មានន័យថា :

ក- ចំពោះព្រះរាជាណាចក្រកម្ពុជា ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានទាំងតំបន់សមុទ្រ រាប់បញ្ចូលទាំងបាត សមុទ្រ និង ស្រទាប់ដីក្រោមបាតសមុទ្រ ដែលជាប់នឹងព្រំដែនខាងក្រៅនៃដែនសមុទ្រ ហើយដែលព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិ គ្រប់គ្រងអធិបតេយ្យភាព និង កាតព្វកិច្ចគ្រប់គ្រងតាមផ្លូវច្បាប់ ដោយអនុលោមតាមច្បាប់អន្តរជាតិ ។

ខ- ចំពោះសាធារណរដ្ឋ សង្គមនិយម វៀតណាម រាល់ទឹកដីគោក ( រាប់បញ្ចូលកោះ ) ទឹកដីសមុទ្រ និង ដែនអាកាសខាងលើ ហើយដែល សាធារណរដ្ឋ សង្គមនិយម វៀតណាម មានសិទ្ធិ គ្រប់គ្រងអធិបតេយ្យភាព និង កាតព្វកិច្ចគ្រប់គ្រងតាមផ្លូវច្បាប់ ដោយអនុលោមតាមច្បាប់អន្តរជាតិ ។

៥ - "ទិន្នផល" ត្រូវមានន័យថា :

ចំណូលបានមកពីការវិនិយោគ ក្នុងរយៈពេលមួយកំណត់ ដូចជា ប្រាក់ចំណេញ ការប្រាក់ ផលកំរៃនៃទុន ប្រាក់ចំណេញនៃភាគហ៊ុន កំរៃឈ្នួល និង កំរៃផ្សេងៗទៀតដែលបានដោយស្របច្បាប់ ។

៦- " រូបិយប័ណ្ណប្រើប្រាស់ដោយសេរី " មានន័យថា:

ជាដុល្លារសហរដ្ឋអាមេរិក -ផោនស្ទែកលីង -ដឺច្ចម៉ាក -ហ្វ្រង់បារាំង -យ៉េនជប៉ុន ឬ រូបិយប័ណ្ណផ្សេងៗទៀត ដែលប្រើប្រាស់ ជាទូលាយក្នុងការទូទាត់អន្តរជាតិ និងដែលធ្វើអាជីវកម្មជាទូលាយ នៅលើទីផ្សារប្តូរប្រាក់អន្តរជាតិសំខាន់ ៗ ។

## មាត្រា ២
## ការជំរុញ និង ការការពារទិនិយោគ

១- ភាគីជាប់កិច្ចសន្យានីមួយៗត្រូវលើកទឹកចិត្តនិងបង្កើតលក្ខណៈអនុគ្រោះដល់ជនជាតិនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ក្នុងការធ្វើវិនិយោគក្នុងទឹកដីរបស់ខ្លួន ហើយទទួលស្គាល់ការវិនិយោគនោះ ដោយអនុលោមតាមរដ្ឋធម្មនុញ្ញ ច្បាប់ និង បទបញ្ញត្តិរបស់ខ្លួន ។

២- រាល់ការធ្វើវិនិយោគដែលធ្វើឡើងដោយជនជាតិ នៃភាគីជាប់កិច្ចសន្យាណាមួយ ត្រូវទទួលបាន នូវប្រព្រឹត្តកម្ម ដោយយុត្តិធម៌ និង សមភាព គ្រប់ពេលវេលា ហើយត្រូវទទួលបាននូវការការពារនិងសន្តិសុខ ពេញលេញ នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ។

## មាត្រា ៣

## បណ្តាប្រការសំរាប់ប្រជាជាតិទទួលការអនុគ្រោះបំផុត

១- ភាគីជាប់កិច្ចសន្យានីមួយ ៗ ត្រូវធានាផ្តល់នូវប្រព្រឹត្តកម្មដោយយុត្តិធម៌ និង សមភាព លើការធ្វើវិនិយោគរបស់ជនជាតិនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត និង មិនធ្វើអោយខូចប្រយោជន៍ដោយវិធានការមិនសមហេតុផល ឬរើសអើង ចំពោះប្រតិបត្តិការ ការគ្រប់គ្រង ការថែរក្សា ការប្រើប្រាស់ ការទទួលផល ឬ ការចាត់ចែងវិនិយោគ របស់ជនជាតិទាំងនោះទេ ។ ភាគីជាប់កិច្ចសន្យានីមួយៗ នឹងផ្តល់ដល់ការវិនិយោគនោះនូវការការពារសន្តិសុខ លើរាងកាយយ៉ាងពេញលេញ ។

២- ជាប្រការសំខាន់ ភាគីជាប់កិច្ចសន្យានីមួយៗ ត្រូវផ្តល់ចំពោះការវិនិយោគទាំងនោះនូវប្រព្រឹត្តកម្ម ដែលនៅគ្រប់ករណី មានភាពអនុគ្រោះមិនតិចជាងអ្វីដែលខ្លួនបានផ្តល់អោយចំពោះការវិនិយោគ ដែលធ្វើឡើង ដោយជនជាតិនៃរដ្ឋទីបី នោះឡើយ ។

៣- ប្រសិនបើភាគីជាប់កិច្ចសន្យាមួយ បានផ្តល់អោយនូវអត្ថប្រយោជន៍ពិសេស ដល់ជនជាតិនៃរដ្ឋទីបីណាមួយ ដោយអាស្រ័យលើកិច្ចព្រមព្រៀងដែលមានស្រាប់ ឬកិច្ចព្រមព្រៀងនាពេលអនាគតក្នុងការបង្កើតនូវសហព័ន្ធគយ សហព័ន្ធសេដ្ឋកិច្ច សហព័ន្ធរូបិយវត្ថុឬស្ថាប័នស្រដៀងៗគ្នានោះ ភាគីជាប់កិច្ចសន្យានោះនឹងពុំត្រូវបង្ខំអោយទទួលកាតព្វកិច្ចក្នុងការផ្តល់អត្ថប្រយោជន៍ដូចគ្នាខាងលើនេះ ដល់ជនជាតិ នៃភាគីជាប់កិច្ចសន្យាម្ខាងទៀតឡើយ ។

៤- ខ្លឹមសារទាំងឡាយនៃមាត្រានេះ នឹងមិនអនុវត្តន៍ចំពោះករណីពន្ធដារ នៅក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យានីមួយៗទេ ។ករណីខាងលើនេះ នឹងត្រូវគ្រប់គ្រងតាមរយៈសន្ធិសញ្ញា ស្តីពីការបញ្ចៀសបង់ពន្ធត្រួតគ្នា រវាងភាគីជាប់កិច្ចសន្យាទាំងពីរ និង /ឬ ច្បាប់ក្នុងស្រុករបស់ភាគីជាប់កិច្ចសន្យានីមួយៗ ។

## មាត្រា ៤
## ការដកហូត

ភាគីជាប់កិច្ចសន្យានីមួយ ៗ មិនអាចចាត់វិធានការណាមួយ ដើម្បីធ្វើការដកហូតទ្រព្យសម្បត្តិតាមវិធីជាតូបនីយកម្ម ឬស្ថិតក្រោមវិធានការដកហូតសិទ្ធិណាមួយផ្សេងទៀត ដែលមានឥទ្ធិពលស្មើគ្នាទៅនឹងជាតូបនីយកម្ម ឬការរឹបអូស ចំពោះការវិនិយោគរបស់ជនជាតិ នៃភាគីជាប់កិច្ចសន្យាម្ខាងទៀតបានឡើយ លើកលែងតែស្ថិតក្នុងល័ក្ខខ័ណ្ឌដូចខាងក្រោមនេះ :

ក-រាល់វិធានការទាំងអស់ដែលបានចាត់ គឺស្ថិតក្នុងគោលបំណងស្របច្បាប់ ដើម្បីជាផលប្រយោជន៍សាធារណៈដោយស្របទៅតាមនីតិវិធីនៃច្បាប់

ខ-វិធានការដែលគ្មានការរើសអើង

គ-វិធានការទាំងអស់ត្រូវផ្សារភ្ជាប់ដោយបណ្តាប្រការ សំរេចចេញជាសំណងយ៉ាងឆាប់រហ័ស ត្រឹមត្រូវ និង មានប្រសិទ្ធិភាព។

សំណងនេះត្រូវផ្អែកលើតំលៃទីផ្សារដ៏ត្រឹមត្រូវនៃការធ្វើវិនិយោគនាមុនពេលដែលបានទទួលការប៉ះពាល់ ហើយមុនពេលដែលវិធានការដកហូតនេះត្រូវបានដឹងជាសាធារណៈ ។

តំលៃទីផ្សារនោះត្រូវបានកំណត់សមស្របទៅតាមវិធីសាស្ត្រ និង ទម្លើ ដែលមានការទទួលស្គាល់ជាអន្តរជាតិ ឬប្រសិនបើតំលៃទីផ្សារមិនអាចកំណត់បានទេនោះ ការប៉ះប៉ូវនឹងត្រូវកំណត់តាមទឹកប្រាក់សមស្របដែលភាគីទាំងពីរបានព្រមព្រៀងគ្នាទៅវិញទៅមក ហើយទឹកប្រាក់នោះអាចផ្ទេរបានដោយសេរី និង គិតជារូបិយវត្ថុដែលអាចប្រើប្រាស់បានដោយសេរីពីភាគីជាប់កិច្ចសន្យា ។

## មាត្រា ៥
## ការទូទាត់សងចំពោះការខាតបង់

១- ជនជាតិទាំងអស់នៃភាគីជាប់កិច្ចសន្យាណាមួយដែលធ្វើវិនិយោគ ក្នុងទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ដែលទទួលរងនូវការខាតបង់ដោយសារតែសង្គ្រាម ឬ ជំលោះអាវុធផ្សេងៗ បដិវត្តន៍ ឬ ការប្រកាសប្រទេសជាតិស្ថិតក្នុងភាពអាសន្ន ការបះបោរ កុប្បកម្មឬ ភាពចលាចល នៅក្នុងទឹកដីនៃភាគីម្ខាងទៀតដែលខ្លួនធ្វើវិនិយោគ នឹងត្រូវបានទទួលពីភាគីជាប់កិច្ចសន្យានោះ នូវប្រព្រឹត្តកម្មដូចជាការសងវិញ សំណង ការទូទាត់សង ឬ ដំណោះស្រាយផ្សេងៗទៀត ។

២- ប្រព្រឹត្តកម្មនេះត្រូវមានលក្ខណៈអនុគ្រោះមិនតិចជាងអ្វីដែលភាគីជាប់កិច្ចសន្យានោះ បានផ្តល់អោយជនជាតិរបស់ខ្លួន ឬ ជនជាតិ នៃរដ្ឋទី ៣ ពោលគឺផ្តល់នូវភាពអនុគ្រោះណាមួយ ដែលមានលក្ខណៈប្រសើរជាង ។

## មាត្រា ៦
## ការផ្ទេរ

១- ភាគីជាប់កិច្ចសន្យានីមួយៗ ដោយអនុលោមទៅតាមច្បាប់និងបទបញ្ញត្តិរបស់ខ្លួន ត្រូវអនុញ្ញាតអោយមានការផ្ទេរដោយសេរី ដោយគ្មានការពន្យាពេលពុំសមហេតុផល នូវអ្វីដែលបានមកពីការវិនិយោគដែលធ្វើឡើងដោយជនជាតិនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ។ ការផ្ទេរនោះត្រូវរាប់បញ្ចូលជាពិសេសតែមិនកំណត់ត្រឹមខ្លឹមសារទាំងនេះឡើយ នូវ :

ក- ប្រាក់ចំណេញ ការប្រាក់ ប្រាក់ចំណេញនៃភាគហ៊ុន និង ប្រាក់ចំណូលផ្សេងៗទៀតដែលបានមកពីវិនិយោគ

ខ- មូលនិធិចាំបាច់

(១) សំរាប់ទិញនូវវត្ថុធាតុដើម ឬ សំភារៈបន្ទាប់បន្សំ ផលិតផលពាក់កណ្តាលសំរេច ឬ ផលិតផលសំរេច ឬ

(២) ជំនួសទុនវិនិយោគ សំដៅធានានិរន្តភាពនៃដំណើរការវិនិយោគ ។

គ- មូលនិធិបន្ថែមចាំបាច់សំរាប់អភិវឌ្ឍន៍ ដំណើរការវិនិយោគ ។

ឃ- មូលនិធិក្នុងការទូទាត់សង នូវប្រាក់កម្ចី ដែលទាក់ទងនឹងការវិនិយោគ ។

ង- កំរៃ ឬ កំរៃស្មោយសារផ្សេងៗ

ច- ចំណូលរបស់រូបវន្តបុគ្គល

ឆ- ចំណូលដែលបានមកពីការលក់ ឬ ការរំលាយវិនិយោគ

ជ- ការទូទាត់សងចំពោះការខាតបង់ ដោយអនុលោមតាមមាត្រា ៥

ឈ- ការទូទាត់សងចំពោះ ការដកហូតតាម ដោយអនុលោមតាមមាត្រា ៤

២- រាល់ការផ្ទេរណាមួយដែលស្ថិតក្រោមកិច្ចព្រមព្រៀងនេះ នឹងត្រូវអនុវត្តតាមរយៈរូបិយប័ណ្ណ ដែលងាយប្តូរបានដោយសេរី ។

អត្រាប្តូរប្រាក់ចំពោះការផ្ទេរនោះនៅក្នុងកថាខ័ណ្ឌទី ១ នៃមាត្រានេះ នឹងត្រូវធ្វើ តាមអត្រាប្តូរប្រាក់ដែលមានជាធរមាននៅពេលផ្ទេរ ។

## មាត្រា ៧

## ឧបាទេសកម្ម

ក្នុងករណីដែលភាគីជាប់កិច្ចសន្យាមួយ បានផ្តល់នូវការធានារ៉ាប់រង ឬ កិច្ចព្រមព្រៀងធានាណាមួយការពារចំពោះហានីភ័យដែលមិនមែនពាណិជ្ជកម្ម ស្តីពីការវិនិយោគដែលបានធ្វើដោយវិនិយោគិនរបស់ខ្លួននៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ហើយមានការទូទាត់ ក្រោមកិច្ចព្រមព្រៀងធានាទៅអោយវិនិយោគិននោះ ភាគីម្ខាងទៀតត្រូវទទួលស្គាល់ការផ្ទេរសិទ្ធិដែលមានតំលៃសេដ្ឋកិច្ចរបស់វិនិយោគិននៃភាគីជាប់កិច្ចសន្យានោះ។ ឧបាទេសកម្មនឹងអាចធ្វើបាន សំរាប់ភាគីជាប់កិច្ចសន្យាមួយ ដើម្បីទទួលយកសំណងនៃការទូទាត់សង ដែលវិនិយោគិនមានសិទ្ធិទទួល។ ប៉ុន្តែឧបាទេសកម្មនេះ មិនចាំបាច់តំរូវអោយមានការទទួលស្គាល់ពីភាគីជាប់កិច្ចសន្យាម្ខាងទៀតឡើយ ស្តីពីគុណសម្បត្តិនៃករណីណាមួយ ឬ បរិមាណទឹកប្រាក់ដែលកើតចេញពីការទាមទារណាមួយ ។

ស្តីពីកម្មសិទ្ធិ ឬ បណ្តាសិទ្ធិដែលបានមកពីភាពជាម្ចាស់នៃការវិនិយោគ ឧបាទេសកម្មនឹងអាចអនុវត្តបានក្រោយពេលដែលតំរូវការផ្នែកច្បាប់សំរាប់ការវិនិយោគ របស់ប្រទេសសាម៉ីម្ចាស់ផ្ទះត្រូវបានបំពេញ ។

## មាត្រា ៨

## ដំណោះស្រាយវិវាទរវាងជនជាតិ និង ភាគីជាប់កិច្ចសន្យា

១- វិវាទណាមួយដែលកើតឡើងរវាងភាគីជាប់កិច្ចសន្យាណាមួយ ជាមួយ ជនជាតិនៃភាគីជាប់កិច្ចសន្យាម្ខាងទៀត ដែលទាក់ទងដល់កិច្ចការវិនិយោគរបស់ខ្លួននៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាម្ខាងទៀតនោះនឹងត្រូវដោះស្រាយដោយមិត្តភាព តាមរយៈការពិគ្រោះយោបល់ និង ការចរចា ។

២- ប្រសិនបើវិវាទនោះមិនអាចដោះស្រាយបាន ក្នុងរយៈពេល៦ខែ ចាប់ពីការជូនដំណឹងជាលាយលក្ខណ៍អក្សរពីសំណាក់ភាគីណាមួយ តាមដំណោះស្រាយជាមិត្តភាពទេនោះ ជំលោះនោះនឹងត្រូវបញ្ជូន

ដោយជនជាតិដែលមានបញ្ហាទៅតាមនីតិវិធីតុលាការនៃភាគីពាក់ព័ន្ធ ឬ ទៅមជ្ឈត្តវិនិច្ឆ័យអាជ្ញាកណ្តាល ឬ ការសំរុះសំរួលអន្តរជាតិ ។

៣- ក្នុងករណីជំលោះត្រូវបានបញ្ជូនទៅមជ្ឈត្តវិនិច្ឆ័យ ឬ តាមការផ្សះផ្សា ជនជាតិមានសិទ្ធិដាក់បញ្ហាជំលោះ នោះទៅ :

(ក) មជ្ឈមណ្ឌល អន្តរជាតិ ទទួលបន្ទុកដោះស្រាយជំលោះវិនិយោគ ក្រោមអនុសញ្ញាស្តីពីដំណោះស្រាយវិវាទវិនិយោគរវាងរដ្ឋ និង ជនជាតិ នៃរដ្ឋនានា ដែលបានបើកចំហរការចុះកិច្ចសន្យានៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី កាលពីថ្ងៃទី ១៨ ខែមិនា ឆ្នាំ ១៩៦៥ សំរាប់ករណី ដែលភាគីជាប់កិច្ចសន្យាទាំងពីរបានចូលជាសមាជិកនៃអនុសញ្ញារួចហើយ ឬ

(ខ) តុលាការពិសេស (AD HOC)ដែលបានរៀបចំឡើងតាមវិធាននៃច្បាប់អាជ្ញាកណ្តាល របស់គណៈកម្មាការសហប្រជាជាតិស្តីពីច្បាប់ពាណិជ្ជកម្មអន្តរជាតិ ( UNCITRAL ) ។ ការសំរេចរបស់មជ្ឈត្តករ គឺជាការសំរេចចុងក្រោយ ហើយដែលភាគីជំលោះទាំងពីរត្រូវតែគោរព ។

៤- គ្មានភាគីជាប់កិច្ចសន្យាណាមួយអាចបន្តការពិភាក្សាតាមរយះការទូតលើករណីដែលលើកទៅកាត់ក្តីមុននឹងមានការសំរេចក្តីរួចហើយពីតុលាការ ឬ ករណីតែភាគីជាប់កិច្ចសន្យាណាមួយមិនបានគោរពអនុវត្តសេចក្តីសំរេចរបស់តុលាការអាជ្ញាកណ្តាល។

## មាត្រា ៩

## ការដោះស្រាយវិវាទ រវាង ភាគីជាប់កិច្ចសន្យា

១- វិវាទរវាងភាគីជាប់កិច្ចសន្យាដែលទាក់ទងដល់ការបកស្រាយ ឬ ការអនុវត្តន៍កិច្ចព្រមព្រៀងនេះត្រូវដោះស្រាយតាមផ្លូវទូត បើសិនធ្វើបាន ។

២- ប្រសិនបើវិវាទនោះមិនអាចដោះស្រាយបានទេនោះ ជំលោះនោះត្រូវស្នើឡើងដោយភាគីជាប់កិច្ចសន្យាណាមួយ ទៅតុលាការអាជ្ញាកណ្តាល ។

៣- តុលាការអាជ្ញាកណ្តាលនោះត្រូវបានបង្កើតឡើងទៅតាមករណីដោយឡែកៗ តាមបែបបទដូចតទៅ: ក្នុងរយៈពេល២ខែ ចាប់ពីពេលទទួលពាក្យបណ្តឹងមក ភាគីជាប់កិច្ចសន្យានីមួយៗត្រូវតែងតាំងសមាជិករបស់ខ្លួនម្នាក់ទៅក្នុងតុលាការអាជ្ញាកណ្តាលនោះ ។ បន្ទាប់មកសមាជិកទាំងពីរនេះត្រូវជ្រើសរើសជនជាតិម្នាក់នៃរដ្ឋទី៣ ដែលមានទំនាក់ទំនងផ្លូវទូត ជាមួយភាគីជាប់កិច្ចសន្យាទាំងពីរ ដោយមានការយល់ព្រមពីភាគីជាប់កិច្ចសន្យា ដើម្បីធ្វើជាប្រធានតុលាការអាជ្ញាកណ្តាល ។ប្រធានតុលាការ

មានការយល់ព្រមពីភាគីជាប់កិច្ចសន្យា ដើម្បីធ្វើជាប្រធានតុលាការអាជ្ញាកណ្តាល ។ប្រធានតុលាការអាជ្ញាកណ្តាលនេះ ត្រូវតែងតាំងអោយស្រេចក្នុងរយៈពេល ២ ខែ គិត ពីថ្ងៃ ដែលសមាជិកតុលាការទាំងពីរបានតែងតាំងរួចមក ។

៤- បើក្នុងរយៈពេលដែលបានកំណត់ក្នុងកថាខ័ណ្ឌទី៣នៃមាត្រានេះ ការតែងតាំងជាចាំបាច់នោះមិនអាចធ្វើបាននឹងបើគ្មានកិច្ចព្រមព្រៀងដោយឡែកណាទៀតនោះ ភាគីជាប់កិច្ចសន្យានីមួយៗអាចអញ្ជើញប្រធានតុលាការអន្តរជាតិដើម្បីធ្វើការតែងតាំងជាចាំបាច់នេះ ។ប្រសិនបើប្រធានតុលាការនោះជាជនជាតិ នៃភាគីជាប់កិច្ចសន្យាណាមួយ ឬ មិនអាចបំពេញមុខងារនេះ ដោយប្រការណាមួយបាននោះ អនុប្រធានតុលាការត្រូវបានអញ្ជើញអោយធ្វើការតែងតាំងនេះ ។ ប្រសិនបើអនុប្រធាននោះគឺជាជនជាតិនៃភាគីជាប់កិច្ចសន្យាណាមួយ ឬ មិនអាចបំពេញកិច្ចការ ខាងលើបានទៀតដែរនោះ សមាជិករបស់តុលាការយុត្តិធម៌អន្តរជាតិ ដែលមានឋានៈបន្ទាប់ តែមិនមែនជាជន ជាតិនៃភាគីជាប់កិច្ចសន្យាណាមួយឡើយ ត្រូវបានអញ្ជើញអោយធ្វើការតែងតាំងនេះ ។

៥- តុលាការអាជ្ញាកណ្តាល ត្រូវកំណត់នូវនីតិវិធីការងារសំរាប់ដំណើរការរបស់ខ្លួន និង ត្រូវធ្វើការសំរេចក្តីដោយការបោះឆ្នោតយកសំឡេងភាគច្រើន ។ ការសំរេចក្តី នោះត្រូវមានប្រសិទ្ធិភាពអនុវត្តសំរាប់ភាគីជាប់កិច្ចសន្យាទាំងពីរ ។

៦- ភាគីជាប់កិច្ចសន្យានីមួយៗត្រូវទទួលរ៉ាប់រងចេញនូវសោហ៊ុយចំណាយសំរាប់សមាជិកអាជ្ញាកណ្តាលរបស់ខ្លួន និង សំរាប់អ្នកតំណាងរបស់ខ្លួនក្នុងដំណើការដំណោះស្រាយវិវាទរបស់អាជ្ញាកណ្តាល ។ តម្លៃចំណាយទៅលើប្រធានតុលាការអាជ្ញាកណ្តាល និងចំណាយដែលនៅសេសសល់ទៀត គឺជាបន្ទុកដែលភាគីទាំងពីរត្រូវទទួលចំណាយដោយស្មើគ្នា ។ប៉ុន្តែតុលាការអាចធ្វើការសំរេចក្តីអោយភាគីជាប់កិច្ចសន្យាណាមួយចេញចំណាយខ្ពស់ជាងភាគីម្ខាងទៀត ។ ការសំរេចក្តីរបស់តុលាការគឺជាការសំរេចចុងក្រោយដែលភាគីទាំងពីរត្រូវតែអនុវត្ត ។

## មាត្រា ១០
## វិសាលភាពគ្របដណ្តប់ នៃ កិច្ចព្រមព្រៀង

កិច្ចព្រមព្រៀងនេះមានវិសាលភាពគ្របដណ្តប់ចំពោះការវិនិយោគនៃភាគីជាប់កិច្ចសន្យាណាមួយដែលធ្វើ និង បានទទួលស្គាល់នៅលើទឹកដីនៃភាគីជាប់កិច្ចសន្យាណាមួយ ដោយអនុលោមទៅតាមច្បាប់ និង បទបញ្ញត្តិ ដែលទាក់ទងនឹង វិនិយោគបរទេស ឬ បណ្តាច្បាប់ដែលបានធ្វើវិសោធនកម្ម ឬជំនួស ច្បាប់នោះ ប៉ុន្តែមិន អាចអនុវត្តចំពោះរាល់ជំលោះ ការតវ៉ា និង ទំនាស់ផ្សេងៗទៀត ដែលបានកើតឡើងមុនការចូលជាធរមាន នៃកិច្ចព្រមព្រៀងនេះឡើយ ។

## មាត្រា១១
## ការអនុវត្តន៍បណ្តាប្រការផ្សេងៗទៀត

ប្រសិនបើបណ្តាមាត្រានៃច្បាប់របស់ភាគីជាប់កិច្ចសន្យាណាមួយឬកាតព្វកិច្ចនៃច្បាប់អន្តរជាតិដែលបានបង្កើត នាពេលបច្ចុប្បន្នឬបានបង្កើតឡើងក្រោយមករវាងភាគីជាប់កិច្ចសន្យាទាំងពីរ ដើម្បីបំពេញបន្ថែមលើកិច្ចព្រម ព្រៀងបច្ចុប្បន្ន ហើយបានចែងនូវបទបញ្ញត្តិមានលក្ខណៈទូទៅ ឬពិសេស សំរាប់ការងារវិនិយោគរបស់ជន ជាតិនៃភាគីជាប់កិច្ចសន្យាផ្សេងទៀតនូវប្រព្រឹត្តកម្ម ដែលមានអំណោយផលជាងអ្វី ដែលបានផ្តល់ដោយកិច្ច ព្រមព្រៀងបច្ចុប្បន្ន បទបញ្ញត្តិនោះត្រូវតែផ្តល់ភាពអំណោយផលជាបន្ថែមសំរាប់កិច្ចព្រមព្រៀងបច្ចុប្បន្ននេះ ដែរ ។

## មាត្រា ១២
## ការពិគ្រោះយោបល់ និង ការធ្វើវិសោធនកម្ម

១- ភាគីជាប់កិច្ចសន្យានីមួយ ៗ អាចស្នើអោយមានការជួបពិគ្រោះយោបល់លើរាល់បញ្ហាដែលទាក់ទង នឹង កិច្ចព្រមព្រៀងនេះ ។ ភាគីម្ខាងទៀតត្រូវផ្តល់ការយកចិត្តទុកដាក់ចំពោះសំណើនេះ ហើយត្រូវផ្តល់ពេលវេលា គ្រប់គ្រាន់ សំរាប់ការពិគ្រោះយោបល់ ។

២-កិច្ចព្រមព្រៀងនេះអាចធ្វើវិសោធនកម្មគ្រប់ពេលវេលា បើសិនជាមានការចាំបាច់ ដោយមានការយល់ ព្រមពីភាគីជាប់កិច្ចសន្យាទាំងពីរ ។

ង.ង

## មាត្រា ១៣

## ការចូលជាធរមាន ថេរវេលា និង ការបញ្ចប់

១- កិច្ចព្រមព្រៀងនេះនឹងចូលជាធរមាននៅថ្ងៃទីមួយ នៃខែបន្ទាប់ពីការជូនដំណឹងចុងក្រោយជាលាយលក្ខណ៍អក្សររបស់ភាគីជាប់កិច្ចសន្យាតាមរយៈផ្លូវទូតថា តំរូវការផ្នែកច្បាប់ក្នុងប្រទេសសំរាប់ការចូលជាធរមាន នៃកិច្ចព្រមព្រៀងត្រូវបានបំពេញរួចរាល់ហើយ ។

២- កិច្ចព្រមព្រៀងនេះមានសុពលភាពអនុវត្តរយៈពេលដប់(១០)ឆ្នាំ ហើយត្រូវនៅបន្តមានសុពលភាពបន្ថែមទៀតរហូតដល់ភាគីជាប់កិច្ចសន្យាណាមួយ បានជូនដំណឹងជាលាយលក្ខណ៍អក្សរទៅភាគីជាប់កិច្ចសន្យាម្ខាងទៀតនូវគោលបំណងថាចង់បញ្ចប់កិច្ចព្រមព្រៀងនេះ។ សេចក្តីជូនដំណឹង ពីការបញ្ចប់នេះ នឹង ចាប់ចូលជាធរមានរយៈពេលមួយឆ្នាំក្រោយថ្ងៃជូនដំណឹង។

៣- ចំពោះការវិនិយោគដែលបានធ្វើមុនថ្ងៃ ដែលការជូនដំណឹងពីការបញ្ចប់កិច្ចព្រមព្រៀងចូលជាធរមាន បណ្តាខ្លឹមសារនៃមាត្រា ១ ដល់១២ ត្រូវស្ថិតនៅជាធរមានបន្តសំរាប់រយៈពេលដប់(១០)ឆ្នាំទៀត ដោយចាប់គិតពីថ្ងៃបញ្ចប់កិច្ចព្រមព្រៀងនេះ ។

ដើម្បីជាសាក្សីនៃកិច្ចព្រមព្រៀងនេះ អ្នកតំណាងស្របច្បាប់ដែលរដ្ឋាភិបាលរៀងខ្លួនបានប្រគល់អំណាចត្រឹមត្រូវមានសិទ្ធិគ្រប់គ្រាន់ក្នុងការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនេះ ។

កិច្ចព្រមព្រៀងនេះធ្វើឡើងចំនួន ២ ច្បាប់នៅ ភ្នំពេញថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០១ ជាភាសាខ្មែរ ភាសាវៀតណាម និង ភាសាអង់គ្លេស អត្ថបទទាំងអស់នេះមានតំលៃគតិយុត្តិស្មើៗគ្នា ។ ក្នុងករណីមានការបកស្រាយមិនស្របគ្នា នោះអត្ថបទជាភាសាអង់គ្លេស ត្រូវបានយកមកធ្វើជាសំអាង ។

**តំណាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា**

**ចម ប្រសិទ្ធ**
**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**អនុប្រធាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**តំណាងរដ្ឋាភិបាលនៃសាធារណរដ្ឋសង្គមនិយមវៀតណាម**

**ឡាយ ខ្វាងធីក**
**អនុរដ្ឋមន្ត្រីក្រសួងផែនការ និងវិនិយោគ**